# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៧-៩-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៩១៦/៨៣២ ស្តីពី ការតែងតាំងឯកឧត្តម **កែន សត្ថា** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ១ ជាអភិបាល នៃគណៈអភិបាលខេត្តកែប សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល | ៨៣៣៥ |
| ២៧-៩-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៩១៦/៨៣៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៤រូប | ៨៣៣៦ |
| ២៧-៩-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៩១៦/៨៣៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ដល់លោកឧត្តមសេនីយ៍ត្រី **មាស ឈុនឡេង** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ៨៣៣៧ |
| ២៧-៩-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៩១៦/៨៣៥ ស្តីពី ការតែងតាំងលោក **ស្នួរ វិរៈ** ជា ឧកញ៉ា | ៨៣៣៨ |


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ២៨-៩-២០១៦ | -អនុក្រឹត្យលេខ ២០០ អនក្រ.បក ស្តីពី ការផ្ទេរតណទានថវិកា | ៨៣៣៩ |
| ២៨-៩-២០១៦ | -អនុក្រឹត្យលេខ ២០១ អនក្រ.បក ស្តីពី ការផ្ទេរតណទានថវិកា | ៨៣៤១ |
| ២៨-៩-២០១៦ | -អនុក្រឹត្យលេខ ២០២ អនក្រ.បក ស្តីពី ការទទួលស្គាល់វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង | ៨៣៤៣ |
| ២៨-៩-២០១៦ | -អនុក្រឹត្យលេខ ២០៣ អនក្រ.បក ស្តីពី ការបង្កើតមន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា | ៨៣៤៦ |
| ២២-៩-២០១៦ | -អនុក្រឹត្យលេខ ៩៥៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៨៣៤៩ |
| ២២-៩-២០១៦ | -អនុក្រឹត្យលេខ ៩៥៧ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន | ៨៣៥១ |
| ២៦-៩-២០១៦ | -អនុក្រឹត្យលេខ ៩៥៨ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ៨៣៥២ |
| ២៦-៩-២០១៦ | -អនុក្រឹត្យលេខ ៩៥៩ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងនាយនគរបាលជាតិ | ៨៣៥៣ |

២៦-៩-២០១៦ -អនុក្រឹត្យលេខ ៩៦០ អនក្រ.បក ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៣៥៤

២៦-៩-២០១៦ -អនុក្រឹត្យលេខ ៩៦១ អនក្រ.បក ស្តីពី ការដំឡើងឋានន្តរស័ក្តិ នាយទាហាន ៨៣៥៦

២៧-៩-២០១៦ -អនុក្រឹត្យលេខ ៩៦២ អនក្រ.បក ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៨៣៥៨

២៧-៩-២០១៦ -អនុក្រឹត្យលេខ ៩៦៣ អនក្រ.បក ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៨៣៥៩

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៦-៩-២០១៦ -ប្រកាសលេខ ១០៣៣ សហវ.ប្រក ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៨៣៦១

២១-៩-២០១៦ -ប្រកាសរួមលេខ ១០៣៩ សហវ.ប្រក ស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៨៣៦៩

២១-៩-២០១៦ -ប្រកាសរួមលេខ ១០៤០ សហវ.ប្រក ស្តីពី ការផ្តល់រង្វាន់លើកទឹកចិត្តលើការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈ ដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៨៣៧៩

### ២-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

២៩-៧-២០១៦ -ប្រកាសលេខ ៤៣១ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ចាផាណាថេកនីខល សេនធ័រ (ខេមបូឌា) បង្កើតរោងចក្រ ផលិតស្បែកជើង ៨៣៨៤

២៩-៧-២០១៦ -ប្រកាសលេខ ៤៣២ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជី.អេស.អេឡិកថេក (ខេមបូឌា) អ៊ីន បង្កើតរោងចក្រ ផលិតខ្សែគ្រឿងអេឡិកត្រូនិក ៨៣៨៧

២៩-៧-២០១៦ -ប្រកាសលេខ ៤៣៣ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីលីត (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៣៩០

២៩-៧-២០១៦ -ប្រកាសលេខ ៤៣៤ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេខេអិន អីវែរីល បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៣៩៣

២៩-៧-២០១៦ -ប្រកាសលេខ ៤៣៥ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ី អិម ប៊ី ជែលកូរី (ខេមបូឌា) បង្កើតរោងចក្រ ប៉ាក់សម្លៀកបំពាក់ ៨៣៩៦

២៩-៧-២០១៦ -ប្រកាសលេខ ៤៣៦ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន បាវ មេន អ៊ិនដាសស្ទ្រី ឯ.ក បង្កើតរោងចក្រ កែច្នៃកៅស៊ូ ៨៣៩៩

២៩-៧-២០១៦ -ប្រកាសលេខ ៤៣៧ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន មេរីខាន ហ្វេសិន (ខេមបូឌា) លីមីធីត បង្កើតសាខារោងចក្រ បោកគក់សម្លៀកបំពាក់ ៨៤០២
២៩-៧-២០១៦ -ប្រកាសលេខ ៤៣៨ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី អិម ស៊ី ដាប់បែលយូ (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៤០៥
២៩-៧-២០១៦ -ប្រកាសលេខ ៤៣៩ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ថប ហ្វេម ហ្គាមេន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៤០៨
០១-៨-២០១៦ -ប្រកាសលេខ ៤៤០ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ីរ៉ូតា (ខេមបូឌា) ហ្គាម៉ិន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៤១១
០១-៨-២០១៦ -ប្រកាសលេខ ៤៤១ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អិន ឃីយ៉ុង (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៤១៤
០៣-៨-២០១៦ -ប្រកាសលេខ ៤៤២ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជី-ហ្វម៉ូស (ខេមបូឌា) បង្កើតរោងចក្រ ផលិតស្បែកជើង ៨៤១៧
០៥-៨-២០១៦ -ប្រកាសលេខ ៤៤៣ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីវតា បង្កើតរោងចក្រ ផលិតខ្សែយឺតចង្កេះខោ ៨៤២០
០៥-៨-២០១៦ -ប្រកាសលេខ ៤៤៤ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សាមីល ខេមបូ បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៤២៣
០៥-៨-២០១៦ -ប្រកាសលេខ ៤៤៥ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន កាដា អ៉ីភែរីល ខប បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៤២៦
០៩-៨-២០១៦ -ប្រកាសលេខ ៤៤៦ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សានយ៉ន (អូវើរស៊ី) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៤២៩
០៩-៨-២០១៦ -ប្រកាសលេខ ៤៤៧ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប៊ីយូធី ស៊ីល ស្គ្រីន លីមីធីត បង្កើតសាខារោងចក្រ ប៉ាក់ និងបោះពុម្ពសម្លៀកបំពាក់ ៨៤៣២
០៩-៨-២០១៦ -ប្រកាសលេខ ៤៤៨ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឃីង លឹម ហ្គាមេន អ៊ែកសេស៊ីរី បង្កើតរោងចក្រ បោះពុម្ពលើស្លាកសញ្ញាសម្លៀកបំពាក់ ៨៤៣៥
០៩-៨-២០១៦ -ប្រកាសលេខ ៤៤៩ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន គួ តាយ ហ័រ សេង ស៊ីន ហ្វេង ជីង (ខេមបូឌា) ហ្គាម៉ិន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៤៣៨
០៩-៨-២០១៦ -ប្រកាសលេខ ៤៥០ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខូវ៉ាបុន (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ ផលិតគ្រឿងបង្គុំកៅអីរថយន្ត ៨៤៤១

១២-៨-២០១៦ -ប្រកាសលេខ ៤៥១ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អូលីវ អ៊ីភែរីល (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨៤៤៤

១២-៨-២០១៦ -ប្រកាសលេខ ៤៥២ ឧស.កឧ.ប្រក.០៨ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប្រាយ សិន អ៊ិនធើណេសិនណល ខបភើរេសិន បង្កើតរោងចក្រ ផលិតស្បែកជើង ៨៤៤៧

## ៣-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

២៨-៩-២០១៦ -សេចក្តីសម្រេចលេខ ១៥២ សសរ សក ស្តីពី ការកែសម្រួលគណៈកម្មការវិវិចទាលទ្ធកម្ម (Procurement Review Committee-PRC) គណៈកម្មការវាយតម្លៃជ្រើសរើស ក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស (Consultant Evaluation Committee-CEC) និង គណៈកម្មការវាយតម្លៃជ្រើសរើសក្រុមហ៊ុនសាងសង់ (Bid Evaluation Commitee -BEC) សម្រាប់គម្រោងលើកកម្រិតផ្លូវជាតិលេខ ៤៨ ពីបំបែកផ្លូវជាតិលេខ ៤ (ចំការហ្លួង) ដល់ ទីរួមខេត្តកោះកុង ក្រោមឥណទានសហប្រតិបត្តិការពីសាធារណរដ្ឋ កូរ៉េ ៨៤៥០

២៨-៩-២០១៦ -ប្រកាសលេខ ១៥៣ ប្រក.សក ស្តីពី ការកែសម្រួលអង្គភាពគ្រប់គ្រង និងតាមដានគម្រោងលើកកម្រិតផ្លូវជាតិលេខ ៤៨ ពីបំបែកផ្លូវជាតិលេខ ៤ (ចំការហ្លួង) ដល់ទីរួមខេត្តកោះកុងក្រោមឥណទានសហប្រតិបត្តិការពីសាធារណរដ្ឋ កូរ៉េ ៨៤៥៣

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៦/៨៣២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **កែន សត្ថា** ឋាននន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ១ ជាអភិបាល នៃគណៈអភិបាលខេត្តកែប សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស. ១៦០៩. ៨៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦

លេខ: ៨៣១ ស.ណ
សំណៅចែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៦/៨៣៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- ឧត្តមសេនីយ៍ទោ **ខៀវ ចាន់រ៉ា** អត្តលេខ ០៧៩៨
២- ឧត្តមសេនីយ៍ទោ **យឹម ឋិរៈ** អត្តលេខ ០៨៨៨
៣- ឧត្តមសេនីយ៍ទោ **ប៉ុណ្ណា សំខាន់** អត្តលេខ ១២២៩៥
៤- ឧត្តមសេនីយ៍ទោ **ស៊ីន រ៉ូ** អត្តលេខ ០១៤៨៦ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៨៣២ ស.ណ
សំណៅចម្លងចេញពីច្បាប់ដើម សម្រាប់ការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា

៣៧.១៦០៩.៨៤៦

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៦/៩៣៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៥០១/១៧៨ចុះថ្ងៃទី២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ដល់លោកឧត្តមសេនីយ៍ត្រី **មាស ឈុនឡេង** អត្តលេខ ០៤៧២៦ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៩៣៣ ស.ណ
សំណៅចែកចាយតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

៣៩៧-១៦០៩.៩៤៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៦/ ៨៣៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ត្រាស់បង្គាប់**

**តែងតាំង :**

**លោក ស្ងួរ វីរៈ**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៦០៩. ៨៤៨

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦

លេខ: ៨៣៥ ស.ណ
សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧០០ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៩០៨ ៨០០ ០០០ រៀល( ប្រាំបួនរយ ប្រាំបីលាន ប្រាំបីរយពាន់រៀល ) ពីជំពូក៦២ (អត្ថប្រយោជន៍សង្គម) មកជំពូក៦១ (សេវាកម្ម ) ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧០១ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១៩០ ០០០ ០០០ រៀល (មួយរយកៅសិបលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទ និងកិច្ចប្រជុំលើកទី ១៣ នៃបណ្តាញអន្តរជាតិស្តីពីទឹក និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងស្រែ ឆ្នាំ ២០១៦ នៅរាជធានីភ្នំពេញ និងខេត្តសៀមរាបចាប់ពីថ្ងៃទី ០៦ ដល់ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៦។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧០៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់វិទ្យាស្ថាន ទ៉ាន់ជាបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- បានឃើញប្រកាសលេខ២២៧ ក.ប/ប្រ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់ វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១ .-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនមួយ ដែលមានឈ្មោះថា «វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង» ឈ្មោះជាភាសាអង់គ្លេស «Vanda Institute of Battambang» សរសេរកាត់ជាភាសាខ្មែរ «វដ-បប» និងសរសេរកាត់ជាភាសាអង់គ្លេស «VI-BB»។

**មាត្រា២ .-**

វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង មានទីតាំងស្ថិតនៅដីឡូត៍លេខ២៧១ ផ្លូវលេខ៦១៤ ភូមិរំចេក២ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។ វិទ្យាស្ថាននេះស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះណ្តាលវិជ្ជាជីវៈ។

**មាត្រា៣ .-**

វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង មានភារកិច្ចធ្វើការបណ្តុះបណ្តាលៈ

- កម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម ០១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ០២ឆ្នាំ ដែលមានយ៉ាងតិច ៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស ឬសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច ០៤ឆ្នាំ ដែលមានយ៉ាងតិច ១២០ក្រេឌីត។

នៅថ្ងៃអនាគត វិទ្យាស្ថាននេះអាចបើកសាខា ដេប៉ាតឺម៉ង់ មហាវិទ្យាល័យ ដំឡើងកម្រិត ប្តូរទីតាំងឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៤ .-**

វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដ៏ទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃវិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥ .-**

នាយកវិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង មានភារកិច្ចដូចខាងក្រោមៈ

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសសិស្សឱ្យចូលរៀន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានកំណត់អំពីសកម្មភាពនៃការធានាគុណភាពតាមវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ជូននាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានទៀងទាត់តាមការកំណត់។

**មាត្រា៦ ._**

សិស្ស-និស្សិតដែលបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រ តាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះ ត្រូវផ្តល់ដោយវិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង ដែលមានការទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថានបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៧ ._**

ប្រកាសលេខ២២៧ ក.ប/ប្រ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តបាត់ដំបង
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧០៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១** .-

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា** (MEKONG Notary Public of the Kingdom of Cambodia) សរសេរកាត់ជាភាសាខ្មែរ "**ម.ស.ម.**" និងសរសេរកាត់ជាភាសាអង់គ្លេស "**M.N.P.**"។

**មាត្រា២ .-**

ត្រូវបានតែងតាំងជាសារការីនូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១-លោកស្រី **ចាំង ស្រីពៅ** ដើម្បីបំពេញមុខងារជាប្រធាននៃមន្ទីរសារការីមេគង្គ
២-លោក **សៅ ធឿន** ដើម្បីបំពេញមុខងារជាអនុប្រធាននៃមន្ទីរសារការីមេគង្គ
៣-លោក **ប៉ាន់ វាសនា** ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីមេគង្គ
៤-លោក **ផង់ វិចិត្រ** ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីមេគង្គ។

ក្នុងករណីចាំបាច់ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើការជ្រើសរើសសារការី ដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀត សម្រាប់ជួយបំពេញតួនាទី និងភារកិច្ច របស់ខ្លួនបាន។

**មាត្រា៣ .-**

មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅផ្ទះលេខ ២២ ផ្លូវលេខ ២៨១ ភូមិទី១៤ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ មន្ទីរសារការីត្រូវជូនដំណឹងមកក្រសួងយុត្តិធម៌។

**មាត្រា៤ .-**

មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែង ទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបាន យថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់ តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និង លិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ .-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ប្រាក់តម្កល់ខាងលើនេះត្រូវបង្វិលជូនស្ថាបនិក និងសហភាគាដែលមានសិទ្ធិក្នុងការទទួល បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានា ដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហភាគា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដែលត្រូវអនុម័តដោយ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៥៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយការងារ
# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា

## សម្រេច

**មាត្រា ១** - បំពាក់ **មេដាយមាសការងារ** ប្រគេនព្រះសង្ឃចំនួន ៧៥ អង្គ ដែលមានស្នាព្រះហត្ថល្អក្នុងការចូលរួមបម្រើសកម្មភាពមនុស្សធម៌របស់កាកបាទក្រហមកម្ពុជា នាពេលកន្លងមកដូចមានរាយព្រះនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ព្រះភិក្ខុ | **គល់ សុខុម** | ៣៩- ព្រះភិក្ខុ | **ណាំង ម៉ុនណារ៉ា** |
| ២- ព្រះភិក្ខុ | **ប៊ិន សុវណ្ណា** | ៤០- ព្រះភិក្ខុ | **គួ សុភាព** |
| ៣- ព្រះភិក្ខុ | **រ៉ែត ផែង** | ៤១- ព្រះភិក្ខុ | **ទង់ តុន** |
| ៤- ព្រះភិក្ខុ | **ឡៅ ម៉ុនលី** | ៤២- ព្រះភិក្ខុ | **យ៉ា រិន** |
| ៥- ព្រះភិក្ខុ | **ថូ គីមថុល** | ៤៣- ព្រះភិក្ខុ | **សយ សុខហេង** |
| ៦- ព្រះតេជគុណ | **នឿន គីមសាន** | ៤៤- ព្រះភិក្ខុ | **ស្វ ចំរើន** |
| ៧- ព្រះតេជគុណ | **មាស សាខន** | ៤៥- ព្រះភិក្ខុ | **គឹម លុច** |
| ៨- ព្រះព្រហ្មជោតោ | **ម៉ា ឆារី** | ៤៦- ព្រះភិក្ខុ | **ហៃ សុខលី** |
| ៩- ព្រះភិក្ខុ ធម្មរក្ខិតោ | **យ៉េត ដារ៉ា** | ៤៧- ព្រះភិក្ខុ | **ពិន សុម៉ុន** |
| ១០- ព្រះភិក្ខុ អគ្គមេតោ | **ឌុល សុខា** | ៤៨- ព្រះភិក្ខុ | **ឌី សារឿន** |
| ១១- ព្រះភិក្ខុ ញាណត្ថេនោ | **រស់ សម្បត្តិ** | ៤៩- ព្រះភិក្ខុ | **ឈឹម ប៉ូ** |
| ១២- ព្រះភិក្ខុ សុវណ្ណបញ្ញោ | **ពួន សុខឃុន** | ៥០- ព្រះភិក្ខុ | **ប៉ូ សុខខុន** |
| ១៣- ព្រះភិក្ខុ ធម្មប្បញ្ញោ | **អឿន មាឃ** | ៥១- ព្រះភិក្ខុ | **សោម ទិន** |

១៤- ព្រះភិក្ខុ បវរមុនី **ភុច ភារម្យ**
១៥- ព្រះភិក្ខុ បញ្ញោធជោ **សួរ សុចិម**
១៦- ព្រះភិក្ខុ ពុទ្ធរក្ខិតោ **សាយ សំណៀង**
១៧- ព្រះភិក្ខុ ឯកធម្ម **មេន សឿន**
១៨- ព្រះភិក្ខុ កណ្យាណធម្មោ **មាន បារាំង**
១៩- ព្រះភិក្ខុ ឋានធម្មោ **កែវ និន**
២០- ព្រះភិក្ខុ វក្ខិតសោកនោ **វ៉ែម ម៉ិនគឹម**
២១- ព្រះបវរមុនី **ឈិត សុផៃ**
២២- ព្រះសុមេធវង្ស **សុខ ម៉ិនធឿន**
២៣- ព្រះញាណកោសល្យ **យឹម ចំរើន**
២៤- ព្រះភិក្ខុ នន្ទត្ថេរោ **ខាន់ សុវណ្ណា**
២៥- ព្រះភិក្ខុ ធម្មប្បញ្ញោ **យឹម ឯកវត្ថា**
២៦- ព្រះភិក្ខុ ឥន្ទញាណោ **ថៃ ម៉ិនធឿន**
២៧- ព្រះភិក្ខុ សីលសំវរោ **នួច វាសនា**
២៨- ព្រះភិក្ខុ អារទ្ធវីរិយោ **ឈុន វឌ្ឍនា**
២៩- ព្រះភិក្ខុ អធិប្បញ្ញោ **គីម នី**
៣០-ព្រះភិក្ខុ សិវត្ថេរោ **ហាន គឹមសយ**
៣១- ព្រះភិក្ខុ ឧហាត្ថេរោ **ប្រាក់ ឌឿន**
៣២- ព្រះភិក្ខុ ចន្ទប្បញ្ញោ **ព្រហ្ម ចំរើន**
៣៣- ព្រះភិក្ខុ គរុករោ **សួរ ឌួន**
៣៤- ព្រះភិក្ខុ **ហ៊ិន សុផល**
៣៥- ព្រះភិក្ខុ **ពេជ្រ សុធន**
៣៦- ព្រះភិក្ខុ **ប៉ុស ម៉ិនធឿន**
៣៧- ព្រះភិក្ខុ **បាន កុសល្យ**
៣៨- ព្រះភិក្ខុ **ឌិន គួរ៉ាក់**
៥២- ព្រះភិក្ខុ **ឈឿន សុភា**
៥៣- ព្រះភិក្ខុ **ឌឿន ដុន**
៥៤- ព្រះភិក្ខុ **ម៉ិន ភិរុនរះ**
៥៥- ព្រះភិក្ខុ **អៀម ស៊ីអាន**
៥៦- ព្រះភិក្ខុ **ឌឹម ធូក**
៥៧- ព្រះភិក្ខុ **យ៉េន វណ្ណៈ**
៥៨- ព្រះភិក្ខុ **សៀង សុវណ្ណា**
៥៩- ព្រះភិក្ខុ **គង់ សុណ្ណា**
៦០- ព្រះភិក្ខុ **ជី ភន**
៦១- ព្រះភិក្ខុ **យ៉ា ចាន់ឌី**
៦២- ព្រះភិក្ខុ **ធិន ម៉ិនធឿន**
៦៣- ព្រះភិក្ខុ **នៅ ឈាន**
៦៤- ព្រះភិក្ខុ **គុល ថុន**
៦៥- ព្រះភិក្ខុ **ធឿន សារឿន**
៦៦- ព្រះភិក្ខុ **ទែន វ៉ាន់នី**
៦៧- ព្រះភិក្ខុ **ចន្ទន៍ សេរី**
៦៨- ព្រះភិក្ខុ **ម៉ាន់ ម៉ិនធឿន**
៦៩- ព្រះភិក្ខុ **ញ៉ុល កុសល**
៧០- ព្រះភិក្ខុ **ជុំ វ៉ា**
៧១- ព្រះភិក្ខុ **កែវ នាង**
៧២- ព្រះភិក្ខុ **ប៊ិន អ៊ុម**
៧៣-ព្រះគ្រូពុទ្ធរក្ខិតោ **គាន សារ៉ាត**
៧៤- ព្រះភិក្ខុ **រិន ថា**
៧៥- សម្តេចព្រះឧត្តមចារិយាបណ្ឌិត **ឈឹង ម៉ិនឈា**

**មាត្រា ២** - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានកាកបាទក្រហមកម្ពុជា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និងមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា          ជាតិ  សាសនា  ព្រះមហាក្សត្រ

លេខ: ៩៤៧ អនក្រ.បក

## អនុក្រឹត្យ

ស្ដីពី

**ការផ្ទេរក្របខ័ណ្ឌ នាយទាហាន**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

### សម្រេច

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនឧត្ដមសេនីយ៍ត្រី **តេង ស៊ីថា** អត្តលេខ ០០១៩៩៨ សមាជិក ក្រុមស្រាវជ្រាវនយោបាយអប់រំចិត្តសាស្ត្រ នៃក្រុមស្រាវជ្រាវយុទ្ធសាស្ត្រយោធា ថ្នាក់ក្រសួងការពារជាតិ បច្ចុប្បន្នទៅបម្រើការងារក្នុងក្របខ័ណ្ឌ ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩៥៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើនិយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** និយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់តាមអតីតភាពការងារ ដល់ឯកឧត្តម **លាង មុនីរិទ្ធ** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ១ មកឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៥៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ច និងតែងតាំងលោកវរសេនីយ៍ឯក **ស្វាយ ពុទ្ធិសាល** អត្តលេខ ០៤២៥៨ បច្ចុប្បន្នជាប្រធានការិយាល័យព័ត៌មាន នាយកដ្ឋាននគរបាលទេសចរណ៍ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ទៅជា សមាជិកក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៩៦០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនសប្បុរសជនចំនួន ១១ រូប ដែលបានចលនាគៀរគរ និងបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តមង្គលមានលក្ខណ៍** ស្ថិតនៅក្នុងឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-លោកស្រី **ស្លួន សាវី** សប្បុរសជននៅខេត្តតាកែវ
២-លោក **យ៉េម ហេង** សប្បុរសជននៅខេត្តតាកែវ
៣-លោក **ញ៉ឹប នឹម** សប្បុរសជននៅខេត្តតាកែវ
៤-លោក **ឡាយ ម៉ាច** សប្បុរសជននៅខេត្តតាកែវ
៥-លោក **នួន ណាំ** សប្បុរសជននៅខេត្តតាកែវ
៦-លោក **ឃីម ឃន** សប្បុរសជននៅខេត្តតាកែវ
៧-លោក **ឡាយ ពាប់** សប្បុរសជននៅខេត្តតាកែវ

| | | |
|---|---|---|
| ៨-លោក | **ធ្វាក់ អុន** | សប្បុរសជននៅខេត្តតាកែវ |
| ៩-លោក | **ខូន ហៀន** | សប្បុរសជននៅខេត្តតាកែវ |
| ១០-លោក | **អ៊ឹម ធីម** | សប្បុរសជននៅខេត្តតាកែវ |
| ១១-លោក | **ឃឹម សុខ** | សប្បុរសជននៅខេត្តតាកែវ |

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...៩៦១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះ ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ **វរនាទីឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១-វរនាវីទោ | **ជួន** | **ជន** | អត្តលេខ ០១៥៧១៤ | ជំនួយការឯកឧត្តម ស្រ៊ុន សារឿន បញ្ជាការដ្ឋានការពារកោះឆ្មេរ |
| ២-វរនាវីទោ | **តូច** | **សំឡៀង** | អត្តលេខ ១៥៨០៦៥ | នាយ ការិយាល័យទី២ បញ្ជាការដ្ឋានការពារកោះឆ្មេរ |
| ៣-វរនាវីទោ | **ឃិន** | **សារ៉ុន** | អត្តលេខ ០៣១០៦៨ | នាយ ការិយាល័យទី៣ បញ្ជាការដ្ឋានការពារកោះឆ្មេរ |
| ៤-វរនាវីទោ | **រឿង** | **តារុណា** | អត្តលេខ ១៥៨១០៦ | នាយ ការិយាល័យទី៥ បញ្ជាការដ្ឋានការពារកោះឆ្មេរ |
| ៥-វរនាវីទោ | **អេម** | **ប៊ុនធឿន** | អត្តលេខ ០៤១៤៦៤ | នាយ ការិយាល័យហ្វឹកហ្វឺន បញ្ជាការដ្ឋានការពារកោះឆ្មេរ |

| | | | | |
|---|---|---|---|---|
| ៦-វរនាវីទោ | **សាត់** | **ខន** | អត្តលេខ ០២៩៣៧៤ | នាយ ការិយាល័យបច្ចេកទេស បញ្ជាការដ្ឋានការពារកោះឆ្មេរ |
| ៧-វរនាវីទោ | **ពេជ្រ** | **សំណាង** | អត្តលេខ ០២៩៣៨៩ | នាយ ការិយាល័យសុខាភិបាល បញ្ជាការដ្ឋានការពារកោះឆ្មេរ |
| ៨-វរនាវីទោ | **សែត** | **សាំង** | អត្តលេខ ១៥៨០៦១ | នាយ ការិយាល័យអភិវឌ្ឍន៍ បញ្ជាការដ្ឋានការពារកោះឆ្មេរ |
| ៩-វរនាវីទោ | **មិន** | **សុខា** | អត្តលេខ ១៥៨១៩០ | មេបញ្ជាការ កងកាំភ្លើងធំ បញ្ជាការដ្ឋានការពារកោះឆ្មេរ |
| ១០-វរនាវីទោ | **សោម** | **សុខ** | អត្តលេខ ០២៩៣៦៧ | ជំនួយការឯកឧត្តម ស្រ៊ុន សារឿន បញ្ជាការដ្ឋានការពារកោះឆ្មេរ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីកសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៦៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : តែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **ផាត សុផានិត** អត្តលេខ ៦១៧១៦ ជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩២៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ០៤ រូប នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ៖

១- លោកឧត្តមសេនីយ៍ទោ **សេង វណ្ណៈ** អត្តលេខ ០២១៧៨ ពីអធិការ នៃអធិការដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ កិច្ចការនគរបាល ទៅជាប្រធាននាយកដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវកិច្ចការនគរបាល ។

២- លោកឧត្តមសេនីយ៍ទោ **នៃ គា** អត្តលេខ ០២១៤០ ពីអធិការ នៃអធិការដ្ឋានអធិការកិច្ចកិច្ចការនគរបាល ទៅជាប្រធាននាយកដ្ឋានអធិការកិច្ចកិច្ចការនគរបាលរាជធានី-ខេត្ត ។

៣- លោកឧត្តមសេនីយ៍ទោ **លី ឡា** អគ្គលេខ ០២១៣២ ពីអធិការរង នៃអធិការដ្ឋានអធិការកិច្ចកិច្ចការនគរបាល ទៅជាប្រធាននាយកដ្ឋានរដ្ឋបាល-សរុប ។

៤- លោកឧត្តមសេនីយ៍ត្រី **សៅ ខាសនា** អគ្គលេខ ០៤២៩៣ ពីអនុប្រធានលេខាធិការដ្ឋាន ទៅជាប្រធាននាយកដ្ឋានអធិការកិច្ច កិច្ចការនគរបាលថ្នាក់កណ្តាល ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.១០៣៣សហវ.ប្រក

## ប្រកាស
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
### និងប្រធានក្រុមប្រឹក្សានីតិកម្ម

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨.អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ ៨៥៤ សហវ.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ ប្រកាសលេខ ១៥៥៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមការិយាល័យមួយចំនួន ក្រោមឱវាទនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងនាយកដ្ឋាននីតិកម្ម នៃអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ ៩៥៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.–**

ប្រកាសនេះ មានគោលបំណងធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការបំពេញការងារក្នុងក្របខ័ណ្ឌក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២.–**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.–**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះផ្នែកក្រោមឱវាទលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២

## មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម

**ប្រការ៤.–**

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម បំពេញតួនាទីនិងភារកិច្ច ដូចខាងក្រោម÷

- ធ្វើជាសេនាធិការបច្ចេកទេសច្បាប់ និងរដ្ឋបាលជូនក្រុមប្រឹក្សានីតិកម្ម
- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម
- ផ្តល់ប្រឹក្សាច្បាប់ និងការគាំទ្រផ្នែកច្បាប់ ដល់ថ្នាក់ដឹកនាំនិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត តាមការស្នើសុំ ឬតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម
- ដឹកនាំសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម
- លើកសំណើអំពីការបកស្រាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច
- ធ្វើកំណត់ហេតុ និងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម

- បូកសរុបរបាយការណ៍ស្តីពីការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងសេចក្តីព្រាងវិសោធនកម្មពាក់ព័ន្ធ សម្រាប់ដាក់ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច
- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ដាក់ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងវាយតម្លៃ ឬចាត់វិធានការបន្ត
- បូកសរុបរបាយការណ៍ស្តីពីខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យាសំខាន់ៗ ជូនប្រធានក្រុមប្រឹក្សានីតិកម្មពិនិត្យនិងសម្រេច
- លើកសំណើនិងផ្តល់អនុសាសន៍លើដំណោះស្រាយចំពោះពាក្យបណ្តឹង ឬវិវាទនានា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច
- លើកសំណើចាត់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការការពារផលប្រយោជន៍ផ្លូវច្បាប់របស់ក្រសួង ជាមួយស្ថាប័នពាក់ព័ន្ធនានា ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច
- បង្កើតឧបករណ៍ការងារនីតិកម្ម ពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេចដាក់ឱ្យប្រើជាផ្លូវការ
- ផ្សព្វផ្សាយកម្រងច្បាប់និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យជំនាញ កម្រងលិខិតរដ្ឋបាលគំរូ និងកម្រងកិច្ចសន្យាគំរូ ដែលត្រូវបានសម្រេចដាក់ឱ្យអនុវត្តជាផ្លូវការដោយក្រុមប្រឹក្សានីតិកម្ម
- រៀបចំឬសម្របសម្រួលការរៀបចំ និងផ្សព្វផ្សាយព្រឹត្តិបត្រ ទិនានុប្បវត្តិ និងមគ្គុទេសក៍នានា ពាក់ព័ន្ធច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម
- រៀបចំនិងដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យានីតិកម្មនានា តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម
- ចូលរួមពិនិត្យនិងពិភាក្សាជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ឬក្នុងកិច្ចប្រជុំអន្តរក្រសួង លើការងាររៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ តាមការចាត់តាំងរបស់ក្រុមប្រឹក្សានីតិកម្ម
- តម្កល់អត្ថបទគតិយុត្ត នៅក្នុងមជ្ឈមណ្ឌលឯកសារច្បាប់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់គ្រងមជ្ឈមណ្ឌលឯកសារច្បាប់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម។

**ប្រការ៥.-**

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

១- ផ្នែកចំណាយថវិកា និងគណនេយ្យ

២- ផ្នែកចំណូលសារពើពន្ធ

៣- ផ្នែកទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ

៤- ផ្នែកហិរញ្ញវត្ថុឯកជន

៥- ផ្នែកអភិបាលកិច្ច

៦- ផ្នែកព័ត៌មានវិទ្យានីតិកម្ម

៧- ផ្នែកគាំទ្រទូទៅ។

អង្គការលេខនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ៦.**_

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន ជាជំនួយការ។ ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការងារទាំងអស់ របស់លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។ អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់ជូនប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម លើការងាររបស់ផ្នែកពាក់ព័ន្ធ។

ផ្នែកនីមួយៗ ដឹកនាំដោយប្រធាន មួយរូប និងមានសមាជិកមួយចំនួន ជាជំនួយការ។ ប្រធាន និងសមាជិកផ្នែកនីមួយៗ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សានីតិកម្ម។

**ប្រការ៧.**_

ផ្នែកចំណាយថវិកានិងគណនេយ្យ ទទួលបន្ទុកការងារពាក់ព័ន្ធវិស័យហិរញ្ញវត្ថុសាធារណៈ លទ្ធកម្មសាធារណៈ និងគណនេយ្យ ដោយមានភារកិច្ច ដូចតទៅ÷

- ផ្តល់មតិប្រឹក្សាច្បាប់ ពាក់ព័ន្ធវិស័យជំនាញ
- រៀបចំកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធហិរញ្ញវត្ថុសាធារណៈ, កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ, កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធគណនេយ្យ និងកម្រងសម្រង់ផ្សេងៗទៀត តាមការចាំបាច់
- ផ្សព្វផ្សាយ និងណែនាំអនុវត្តនូវកម្រងសម្រង់ក្នុងវិស័យជំនាញ
- ទទួលបន្ទុកការងារច្បាប់ តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សានីតិកម្ម ពាក់ព័ន្ធក្រសួង ស្ថាប័ន រួមមាន÷ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការពារជាតិ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងផែនការ ក្រសួងធនធានទឹកនិងឧតុនិយម អាជ្ញាធរសវនកម្មជាតិ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អនុប្រធានប្រចាំការ និងប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។

**ប្រការ៨.**_

ផ្នែកចំណូលសារពើពន្ធ ទទួលបន្ទុកការងារពាក់ព័ន្ធវិស័យសារពើពន្ធ ដោយមានភារកិច្ច ដូចតទៅ÷

- ផ្តល់មតិប្រឹក្សាច្បាប់ ពាក់ព័ន្ធវិស័យជំនាញ
- រៀបចំកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធពន្ធដារ, កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធគយនិងរដ្ឋាករកម្ពុជា និងកម្រងសម្រង់ផ្សេងៗទៀត តាមការចាំបាច់
- ផ្សព្វផ្សាយ និងណែនាំអនុវត្តនូវកម្រងសម្រង់ក្នុងវិស័យជំនាញ
- ទទួលបន្ទុកការងារច្បាប់ តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សានីតិកម្ម ពាក់ព័ន្ធក្រសួង ស្ថាប័ន រួមមាន÷ ក្រសួងពាណិជ្ជកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងព័ត៌មាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ ក្រសួងធម្មការនិងសាសនា ក្រសួងកិច្ចការនារី
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អនុប្រធានប្រចាំការ និងប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។

**ប្រការ៩.**_

ផ្នែកទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ទទួលបន្ទុកការងារពាក់ព័ន្ធវិស័យទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដោយមានភារកិច្ច ដូចតទៅ÷

- ផ្តល់មតិប្រឹក្សាច្បាប់ ពាក់ព័ន្ធវិស័យជំនាញ

- រៀបចំកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងកម្រងសម្រង់ផ្សេងៗទៀត តាមការចាំបាច់
- ផ្សព្វផ្សាយ និងណែនាំអនុវត្តនូវកម្រងសម្រង់ក្នុងវិស័យជំនាញ
- ទទួលបន្ទុកការងារច្បាប់ តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សានីតិកម្ម ពាក់ព័ន្ធក្រសួង ស្ថាប័ន រួមមាន÷ ក្រសួងព្រះបរមរាជវាំង ក្រសួងរ៉ែនិងថាមពល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អនុប្រធានប្រចាំការ និងប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។

**ប្រការ១០.-**

ផ្នែកហិរញ្ញវត្ថុឯកជន ទទួលបន្ទុកការងារពាក់ព័ន្ធវិស័យឧស្សាហកម្មហិរញ្ញវត្ថុ ដោយមានភារកិច្ច ដូចតទៅ÷

- ផ្ដល់មតិប្រឹក្សាច្បាប់ពាក់ព័ន្ធវិស័យជំនាញ
- រៀបចំកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធឧស្សាហកម្មហិរញ្ញវត្ថុ និងកម្រងសម្រង់ផ្សេងៗទៀត តាមការចាំបាច់
- ផ្សព្វផ្សាយ និងណែនាំអនុវត្តនូវកម្រងសម្រង់ក្នុងវិស័យជំនាញ
- ទទួលបន្ទុកការងារច្បាប់ តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សានីតិកម្ម ពាក់ព័ន្ធក្រសួង ស្ថាប័ន រួមមាន÷ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងធនាគារជាតិ នៃកម្ពុជា
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អនុប្រធានប្រចាំការ និងប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។

**ប្រការ១១.-**

ផ្នែកអភិបាលកិច្ច ទទួលបន្ទុកការងារពាក់ព័ន្ធវិស័យអភិបាលកិច្ច ការបកប្រែភាសា និងការគាំទ្របច្ចេកទេសទូទៅ ដោយមានភារកិច្ច ដូចតទៅ÷

- ផ្ដល់មតិប្រឹក្សាច្បាប់ ពាក់ព័ន្ធវិស័យជំនាញ
- រៀបចំកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងបុគ្គលិក, កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធកិច្ចដំណើរការស្ថាប័ន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, កម្រងសម្រង់បទប្បញ្ញត្តិច្បាប់សំខាន់ៗទាក់ទងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, សទ្ទានុក្រមគតិយុត្ត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ចក្ខុវិស័យនិងយុទ្ធសាស្ត្រ នៃមុខងារនីតិកម្ម, មគ្គុទេសក៍នីតិកម្ម, ការបកប្រែកម្រងសម្រង់ជាភាសាអង់គ្លេស និងកម្រងសម្រង់ផ្សេងៗទៀត តាមការចាំបាច់
- ផ្ដល់កិច្ចគាំទ្រទូទៅផ្នែកបច្ចេកទេស ជូនផ្នែកផ្សេងទៀត តាមការចាំបាច់
- ទទួលបន្ទុកការងារច្បាប់ តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សានីតិកម្ម ពាក់ព័ន្ធក្រសួង ស្ថាប័ន រួមមាន÷ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ ក្រសួងយុត្តិធម៌ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ផ្សព្វផ្សាយ និងណែនាំអនុវត្តនូវកម្រងសម្រង់ក្នុងវិស័យជំនាញ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អនុប្រធានប្រចាំការ និងប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។

**ប្រការ១២.-**

ផ្នែកព័ត៌មានវិទ្យានីតិកម្ម ទទួលបន្ទុកការងារពាក់ព័ន្ធព័ត៌មានវិទ្យានីតិកម្ម ដោយមានភារកិច្ច ដូចតទៅ÷

- រៀបចំ, គ្រប់គ្រង, ធ្វើបច្ចុប្បន្នកម្ម, ធ្វើទំនើបកម្ម និងធ្វើសុខដុមនីយកម្មកម្មវិធីបច្ចេកវិទ្យាព័ត៌មានកម្រងសម្រង់លើទូរសព្ទវៃឆ្លាត, ធេប្លេត និងកុំព្យូទ័រ
- រៀបចំរចនាកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តទាំងអស់ ដើម្បីបោះពុម្ព
- រៀបចំ, បញ្ចូលទិន្នន័យ, គ្រប់គ្រង, បច្ចុប្បន្នកម្ម, ធ្វើទំនើបកម្ម និងធ្វើសុខដុមនីយកម្មប្រព័ន្ធទិន្នន័យផ្ទុកនិងស្វែងរកឯកសារច្បាប់
- រៀបចំ, បញ្ចូលទិន្នន័យ, គ្រប់គ្រង, បច្ចុប្បន្នកម្ម, ធ្វើទំនើបកម្ម និងធ្វើសុខដុមនីយកម្មគេហទំព័រផ្លូវការលើវេបសាយ និងបណ្តាញសង្គមនានា
- រៀបចំ, គ្រប់គ្រង, ធ្វើបច្ចុប្បន្នកម្ម, ធ្វើទំនើបកម្ម និងធ្វើសុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងបុគ្គលិកផ្នែកក្នុងលេខាធិការដ្ឋាន
- គ្រប់គ្រងនិងឆ្លើយតបនូវព័ត៌មានត្រឡប់ ទៅអ្នកប្រើប្រាស់កម្មវិធីបច្ចេកវិទ្យាព័ត៌មានកម្រងសម្រង់, គេហទំព័រផ្លូវការលើវេបសាយ និងបណ្តាញសង្គមនានា
- គាំទ្រទូទៅដល់កិច្ចដំណើរការ នៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម លើផ្នែកបច្ចេកវិទ្យាព័ត៌មាន
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អនុប្រធានប្រចាំការ និងប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។

**ប្រការ១៣.-**

ផ្នែកគាំទ្រទូទៅ ទទួលបន្ទុកការងារពាក់ព័ន្ធការងារគាំទ្រទូទៅ ដោយមានភារកិច្ច ដូចតទៅ÷

- រៀបចំ សម្របសម្រួល ប្រមូលសរុប និងអនុវត្តថវិការបស់លេខាធិការដ្ឋាន
- រៀបចំ សម្របសម្រួល ប្រមូលសរុបរបាយការណ៍វឌ្ឍនភាព នៃលេខាធិការដ្ឋាន
- រៀបចំកន្លែងប្រជុំនិងសិក្ខាសាលារបស់លេខាធិការដ្ឋាន និងក្រុមប្រឹក្សានីតិកម្ម
- រៀបចំ, គ្រប់គ្រង និងបញ្ជូនលិខិតរដ្ឋបាល
- គ្រប់គ្រងនិងស្តែនរាជកិច្ច ឯកសារច្បាប់ និងឯកសារផ្សេងៗទៀត
- គាំទ្រទូទៅដល់កិច្ចដំណើរការ នៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម លើផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អនុប្រធានប្រចាំការ និងប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។

## ជំពូកទី២

## កិច្ចដំណើរការការងារ

**ប្រការ១៤.-**

ក្នុងការបំពេញការងារ ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ផ្នែកដទៃទៀត នៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ប្រធានផ្នែកពាក់ព័ន្ធត្រូវសហការគ្នា ដើម្បីរួមគ្នាដោះស្រាយ ឬសុំការសម្រេចពីថ្នាក់ដឹកនាំលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម លើការបែងចែកភារកិច្ចទាំងនោះ ដោយមានការឯកភាពពីអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម។

ផ្នែកនីមួយៗ អាចសហការរៀបចំកម្រងសម្រង់និងឧបករណ៍ការងារនីតិកម្មផ្សេងទៀត តាមការសម្រេចរបស់ថ្នាក់ដឹកនាំលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ដោយមានការឯកភាពពីអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម។

**ប្រការ១៥.-**

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានរបបប្រជុំប្រចាំខែ ត្រីមាស និងឆ្នាំ ដោយមានការចូលរួមពីគ្រប់សមាសភាពជាថ្នាក់ដឹកនាំនិងមន្ត្រីនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ក្រោមការដឹកនាំរបស់អនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម។

**ប្រការ១៦.-**

ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានភារកិច្ចរៀបចំនិងដឹកនាំកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ប្រចាំខែ។

ផ្នែកនីមួយៗ មានរបបប្រជុំប្រចាំសប្តាហ៍ ដើម្បីពិនិត្យតាមដានវឌ្ឍនភាពការងារ, កំណត់ និងដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តការងាររបស់ខ្លួន។ អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម អាចដឹកនាំនិងសម្របសម្រួលកិច្ចប្រជុំប្រចាំសប្តាហ៍ ឬកិច្ចប្រជុំចំពោះកិច្ចនៃផ្នែកពាក់ព័ន្ធ តាមការចាំបាច់។ ក្នុងករណីមានបញ្ហាប្រឈម ផ្នែកនីមួយៗ ត្រូវរាយការណ៍ ជូនប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតកម្ម ពិនិត្យនិងសម្រេច តាមការចាំបាច់។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៨.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៦

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ ១០៣៣......
ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦

**អង្គការលេខនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៣៩ សហវ.ឈក

## ប្រកាសរួម
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣៩៤០ ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់ទិដ្ឋាការចេញ ចូលច្រើនដង រយៈពេល ១ឆ្នាំ ដល់ ៣ឆ្នាំ ដល់អ្នកទេសចរ និងវិនិយោគិនជប៉ុនដែលកាន់លិខិតឆ្លងដែនធម្មតា
- បានឃើញប្រកាសអន្តរក្រសួងលេខ ៦៧៦ សហវ.ប្រក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកំណត់អាករទិដ្ឋាការ និងអាករទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ន សម្រាប់ជនបរទេសមិនមែនអន្តោប្រវេសន្តចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងកែសម្រួល កិច្ចព្រមព្រៀងប្រព័ន្ធទិដ្ឋាការអេឡិចត្រូនិច E-Visa ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន CINET TECHNOLOGIES CO., LTD.
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .-**

សេវាសាធារណៈ ដែលផ្តល់ដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីតម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៣ .-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសរួម ព្រមទាំងកម្រងសេវាសាធារណៈ រួមទាំងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ ព្រមទាំងទម្រង់ឯកសារ និងនីតិវិធី សម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃសេវាលើសការកំណត់ ឬ មានការយឺតយ៉ាវក្នុងការផ្តល់សេវាសាធារណៈជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់លេខទូរស័ព្ទ សារអេឡិចត្រូនិក បណ្តាញសង្គម ប្រអប់សំបុត្រ និងផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅប្រធានស្ថាប័ន ឬ ប្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៤ .-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ៥ .-**

រាល់ការទទួលប្រាក់ចំណូលជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែការទទួលប្រាក់ចំណូលពីការផ្តល់ទិដ្ឋាការ ដែលអនុញ្ញាតឱ្យប្រើប្រាស់គល់សន្លឹកទិដ្ឋាការជាសក្ខីបត្រសម្រាប់ការកត់ត្រាបញ្ជីគណនេយ្យ។

**ប្រការ៦ .-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន, បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៧ .-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៨ .-**

កម្រៃសេវាសាធារណៈ ដូចមានចែងក្នុងប្រការ២ ខាងលើ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៦ នេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ប្រាក់_សុខុន

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ ១០៣៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៦

ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| I. សេវាដែលផ្តល់ដោយទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | | | |
| ១ | ការផ្តល់ទិដ្ឋាការទេសចរណ៍អេឡិចត្រូនិក (E-Visa) | 37 $ | ភ្លាមៗ | ៣ខែ |
| ២ | បន្តការស្នាក់នៅបណ្តោះអាសន្ន និងកំណត់ការចូល ចេញមួយ ឬច្រើនដង | | | |
| | - ទិដ្ឋាការការទូត (A) | ឥតគិតថ្លៃ | 3ថ្ងៃ | 1ឆ្នាំ |
| | - ទិដ្ឋាការផ្លូវការ (B) | ឥតគិតថ្លៃ | 3ថ្ងៃ | 1ឆ្នាំ |
| | - ទិដ្ឋាការបោរីភាព (C) | ឥតគិតថ្លៃ | 3ថ្ងៃ | 1ឆ្នាំ |
| ៣ | ការផ្តល់ និងការពន្យារសុពលភាពលិខិតឆ្លងដែន | | | |
| | - ការផ្តល់លិខិតឆ្លងដែនការទូត | ឥតគិតថ្លៃ | 7ថ្ងៃ | 3ឆ្នាំ |
| | - ការផ្តល់លិខិតឆ្លងដែនផ្លូវការ | ឥតគិតថ្លៃ | 7ថ្ងៃ | 3ឆ្នាំ |
| | - ពន្យារលិខិតឆ្លងដែនការទូត ឬ លិខិតឆ្លងដែនផ្លូវការ | ឥតគិតថ្លៃ | 7ថ្ងៃ | 3ឆ្នាំ |
| ៤ | ការបញ្ជាក់នីត្យានុកូលកម្មលើឯកសារ (សម្រាប់ការប្រើប្រាស់ផ្លូវការនៅក្រៅប្រទេស) ដោយមិនរួមបញ្ចូលសេវាបកប្រែ | | | |
| | -សំបុត្រកំណើត | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | -សំបុត្រអាពាហ៍ពិពាហ៍ | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -សំបុត្រមរណភាព | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លិខិតបញ្ជាក់ទីលំនៅ | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -ព្រឹត្តបត្រថ្កោលទោស | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -វិញ្ញាបនបត្ររដ្ឋបាល | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -ប័ណ្ណបើកបរ ឬ ប័ណ្ណសម្គាល់យានយន្ត | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -សញ្ញាបត្រគ្រប់ប្រភេទ ឬ ព្រឹត្តិបត្រពិន្ទុ | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -ប័ណ្ណពន្ធប៉ាតង់ ឬ បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ | ៥០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -វិញ្ញាបនបត្របញ្ជាក់អចលនទ្រព្យ | ៥០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លិខិតប្រគល់សិទ្ធកាន់កាប់ប្រើប្រាស់ដីធ្លី / ផ្ទះ | ៥០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -សាលក្រមតុលាការ | ១០០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ | ២០០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | ២០០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |

| ល.រ | បរិយាយ | តម្លៃឯកតា នៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | -វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ | ២០០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លិខិតនាំទំនិញចេញ | ២០០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -អាជ្ញាប័ណ្ណអនុញ្ញាតធ្វើអាជីវកម្ម | ៣០០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លក្ខន្តិកៈក្រុមហ៊ុន | ៣០០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លិខិតផ្សេងៗទៀតដែលចេញដោយអាជ្ញាធរដែនដី | ១០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លិខិតផ្សេងៗទៀតដែលចេញដោយក្រសួង ស្ថាប័ន | ២០០.០០០ រៀល | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥ | ការផ្តល់លិខិតអនុញ្ញាតរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស | ៥០០.០០០ រៀល | 15ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦ | លិខិតបញ្ជាក់លើលក្ខណៈសម្បត្តិអ្នកសុំកូនអន្តរប្រទេស | ២.០០០.០០០ រៀល | 15ថ្ងៃ | អចិន្ត្រៃយ៍ |
| ៧ | ការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាល (បរទេស) | | | |
| | -ចុះបញ្ជីថ្មី | ១.២០០.០០០ រៀល | 45ថ្ងៃ | 3ឆ្នាំ |
| | -បន្តសុពលភាព | ៨០០.០០០ រៀល | 45ថ្ងៃ | 3ឆ្នាំ |
| ៨ | ការផ្តល់ឯកសារសុំស្លាកលេខរថយន្ត | ១០០.០០០ រៀល | 10ថ្ងៃ | អចិន្ត្រៃយ៍ |
| ៩ | ការផ្តល់ឯកសារសុំស្លាកលេខម៉ូតូ | ៦០.០០០ រៀល | 10ថ្ងៃ | អចិន្ត្រៃយ៍ |
| ១០ | ការសុំប្តូរឈ្មោះសញ្ញាសំគាល់ និងត្រា | ៦០.០០០ រៀល | 10ថ្ងៃ | អចិន្ត្រៃយ៍ |

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| II. សេវាដែលផ្តល់ដោយស្ថានតំណាងកម្ពុជាប្រចាំនៅបរទេស | | | | |
| ១ | ការផ្តល់ទិដ្ឋាការ | | | |
| | - ទិដ្ឋាការការទូត (A) | ឥតគិតថ្លៃ | 3ថ្ងៃ | 3ខែ |
| | - ទិដ្ឋាការផ្លូវការ (B) | ឥតគិតថ្លៃ | 3ថ្ងៃ | 3ខែ |
| | - ទិដ្ឋាការចៅរីភាព (C) | ឥតគិតថ្លៃ | 3ថ្ងៃ | 3ខែ |
| | - ទិដ្ឋាការឆ្លងកាត់ (D) | 15 $ | 3ថ្ងៃ | 7ថ្ងៃ |
| | - ទិដ្ឋាការធម្មតា (E) | 35 $ | 3ថ្ងៃ | 3ខែ |
| | - ទិដ្ឋាការធម្មតារយៈពេលពេលវែង (E1) | 50 $ | 3ថ្ងៃ | 1ឆ្នាំ |
| | - ទិដ្ឋាការធម្មតារយៈពេលពេលវែង (E2) | 75 $ | 3ថ្ងៃ | 2ឆ្នាំ |
| | - ទិដ្ឋាការធម្មតារយៈពេលពេលវែង (E3) | 100 $ | 3ថ្ងៃ | 3ឆ្នាំ |
| | - ទិដ្ឋាការពិសេស (K) | ឥតគិតថ្លៃ | 3ថ្ងៃ | ថ្ងៃផុតកំណត់នៃលិខិតឆ្លងដែន |
| | - ទិដ្ឋាការអេកម៉ិក (KHM) | 30 $ | 3ថ្ងៃ | 3ខែ |
| | - ទិដ្ឋាការទេសចរណ៍ (T) | 30 $ | 3ថ្ងៃ | 3ខែ |
| | - ទិដ្ឋាការទេសចរណ៍រយៈពេលវែង (T1) | 40 $ | 3ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃឯកតា នៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - ទិដ្ឋាការទេសចរណ៍រយៈពេលវែង (T2) | 60 $ | 3ថ្ងៃ | 2ឆ្នាំ |
| | - ទិដ្ឋាការទេសចរណ៍រយៈពេលវែង (T3) | 80 $ | 3ថ្ងៃ | 3ឆ្នាំ |
| ២ | ពន្យារលិខិតឆ្លងដែនធម្មតា | ឥតគិតថ្លៃ | 3ថ្ងៃ | 2ឆ្នាំ |
| ៣ | ការបញ្ជាក់នីត្យានុកូលកម្មលើឯកសារ (សម្រាប់ការប្រើប្រាស់ផ្លូវការនៅក្រៅប្រទេស) ដោយមិនរួមបញ្ចូលសេវាបកប្រែ | | | |
| | -សំបុត្រកំណើត | 5 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -សំបុត្រអាពាហ៍ពិពាហ៍ | 5 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -សំបុត្រមរណភាព | 5 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ | 5 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | 5 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លិខិតបញ្ជាក់ទីលំនៅ | 5 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -ព្រឹត្តបត្រថ្កោលទោស | 5 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -វិញ្ញាបនបត្ររដ្ឋបាល | 5 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -ប័ណ្ណបើកបរ ឬ ប័ណ្ណសម្គាល់យានយន្ត | 5 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -សញ្ញាបត្រគ្រប់ប្រភេទ ឬ ព្រឹត្តិបត្រពិន្ទុ | 5 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -ប័ណ្ណពន្ធប៉ាតង់ ឬ បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ | 20 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | -វិញ្ញាបនបត្របញ្ជាក់អចលនទ្រព្យ | 20 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លិខិតប្រគល់សិទ្ធកាន់កាប់ប្រើប្រាស់ដីធ្លី / ផ្ទះ | 20 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -សាលក្រមតុលាការ | 30 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ | 50 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | 50 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ | 50 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លិខិតនាំទំនិញចេញ | 50 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -អាជ្ញាប័ណ្ណអនុញ្ញាតធ្វើអាជីវកម្ម | 100 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លក្ខន្តិកៈក្រុមហ៊ុន | 100 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លិខិតផ្សេងៗទៀតដែលចេញដោយអាជ្ញាធរដែនដី | 10 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| | -លិខិតផ្សេងៗទៀតដែលចេញដោយក្រសួង ស្ថាប័ន | 50 $ | 5ថ្ងៃ | អចិន្ត្រៃយ៍ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១០៥០ សហវ.ប្រក

# ប្រកាសរួម

## ស្តីពី

## ការផ្តល់ទឹកប្រាក់លើកទឹកចិត្តលើការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈ ដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664  Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣៩៤០ ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់ទិដ្ឋាការចេញ ចូលច្រើនដង រយៈពេល ១ឆ្នាំ ដល់ ៣ឆ្នាំ ដល់អ្នកទេសចរ និងវិនិយោគិនជប៉ុនដែលកាន់លិខិតឆ្លងដែនធម្មតា
- បានឃើញកិច្ចព្រមព្រៀងកែសម្រួល កិច្ចព្រមព្រៀងប្រព័ន្ធទិដ្ឋាការអេឡិចត្រូនិច E-Visa ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន CINET TECHNOLOGIES CO., LTD.
- បានឃើញប្រកាសរួមលេខ ១០៣៥ សហវ.ប្រក ចុះថ្ងៃទី២១.. ខែ.កញ្ញា. ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ២ .-**

អនុញ្ញាតឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១៥៣៩ សហវ.ប្រក ចុះថ្ងៃទី២១.. ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទាន សម្រាប់ការចំណាយដូចបានកំណត់នៅក្នុងប្រការ ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៣ .-**

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលដែលប្រមូលបាន និងបែងចែកដូចខាងក្រោម ÷

ក. ចំណូលប្រមូលបានពីការផ្តល់ទិដ្ឋាការ ត្រូវបានកំណត់ដូចតទៅ ÷

១. ទូទាត់ថ្លៃចំណាយជូនក្រុមហ៊ុនដៃគូ ផ្អែកតាមកិច្ចសន្យាជាធរមាន

២. ចំណូលដែលនៅសល់ក្រោយពីបានទូទាត់ថ្លៃចំណាយជូនក្រុមហ៊ុនដៃគូ ត្រូវបានបែងចែក ÷

- បង់ចូលថវិកាជាតិ ចំនួន ៩០% នៃចំណូលដែលនៅសល់
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ១០% នៃចំណូលដែលនៅសល់ ក្នុងនោះមានចំណែករង្វាន់លើកទឹកចិត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០,២%។

ខ. ចំណូលប្រមូលបានពីកម្រៃសេវាសាធារណៈផ្សេងៗទៀត ក្រៅពីចំណុច ក ខាងលើ ត្រូវបានកំណត់ដូចតទៅ ÷

- បង់ចូលថវិកាជាតិ ចំនួន ២០% នៃចំណូលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ៨០% នៃចំណូលប្រមូលបាន ក្នុងនោះមានចំណែករង្វាន់លើកទឹកចិត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលប្រមូលបាន។

**ប្រការ៤ .-**

ជារៀងរាល់ឆ្នាំ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវគ្រោងចំណូលពីការផ្តល់ទិដ្ឋាការគ្រប់ប្រភេទ និងចំណូលផ្សេងៗទៀត ព្រមទាំងគ្រោងឥណទានចំណាយប្រាក់រង្វាន់ ដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទាន (រង្វាន់ដែលបានកាត់ទុក) ពីចំណូលថវិកាជាតិ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដែរ។

**ប្រការ៥ .–**

ការទូទាត់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

ក. ផ្នែកចំណូល: ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើសលាកបត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន និងសំណើសុំកត់ត្រាចំណូល រួចបញ្ជូនមកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកបត្រចំណូលថវិកាជាតិ និងបណ្ណបង់ប្រាក់, តារាងស្តីពីការគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកបត្រចំណូលថវិកាជាតិ។

ខ. ផ្នែកចំណាយ: ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើសំណើសុំទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្ត និងធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកបត្រចំណូលថវិកាជាតិ។

**ប្រការ៦ .–**

ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តដូចខាងក្រោម ÷

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៧ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៨ .-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៦ នេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៦

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ប្រាក់_សុខុន

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៣១....ឧសក.ប្រក.០៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១៦

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ ផលិតស្បែកជើង ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រុមហ៊ុន ចាផាណា ថេកនីខល សេនធ័រ (ខេមបូឌា)។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ចាផាណា ថេកនីខល សេនធ័រ (ខេមបូឌា) (JAPANA TECHNICAL CENTER (CAMBODIA) CO., LTD.) តំណាងដោយ លោក **ATSUSHI MIZUNO** បង្កើតរោងចក្រផលិតស្បែកជើង ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសតាយសេង បាវិត (សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង)។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| ស្បែកជើង | ១៥២០ |

<u>**ប្រការ២៖**</u> ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ " រោងចក្រផលិតស្បែកជើង ចាផាណា ថេកនីខល សេនធ័រ (ខេមបូឌា) "

<u>**ប្រការ៣៖**</u> ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

<u>**ប្រការ៤៖**</u> មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

<u>**ប្រការ៥៖**</u> ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

<u>**ប្រការ៦៖**</u> ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

<u>**ប្រការ៧៖**</u> ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

<u>**ប្រការ៨៖**</u> ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

<u>**ប្រការ៩៖**</u> ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

<u>**ប្រការ១០៖**</u> ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១១៖</u>** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១២៖</u>** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**<u>ប្រការ១៣៖</u>** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**<u>ប្រការ១៤៖</u>** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**<u>ប្រការ១៥៖</u>** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**<u>ចម្លងជូន៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តស្វាយរៀង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៣៤....ឧស.ភឧ.ប្រក-០៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១៦

## ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ ផលិតខ្សែគ្រឿងអេឡិកត្រូនិក របស់ក្រុមហ៊ុន ជី.អេស.អេឡិកថេក (ខេមបូឌា) អ៊ីន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ជី.អេស.អេឡិកថេក (ខេមបូឌា) អ៊ីន (G.S.ELECTECH (CAMBODIA) INC.) តំណាង ដោយ លោក KIMURA TOSHIRO បង្កើតរោងចក្រ ផលិតខ្សែគ្រឿងអេឡិកត្រូនិក ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (សង្កាត់កន្ទោក សង្កាត់ភ្លើងឆេះរទេះ សង្កាត់បឹងធំ) ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ខ្សែគ្រឿងអេឡិកត្រូនិក | ២៦១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រផលិតខ្សែគ្រឿងអេឡិកត្រូនិក ជី.អេស.អេឡិកថេក (ខេមបូឌា) អ៊ីន "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។



៤

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤:** ប្រកាសលេខ ៣៨៦ ឧវ៉ថ.កឧ.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងលិខិតលេខ ១៧៨៦ ឧស.កឧ.លស.០៧ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការបង្កើតរោងចក្រផលិតខ្សែគ្រឿងអេឡិកត្រូនិក របស់ក្រុមហ៊ុន ជី.អេស.អេឡិកថេក (ខេមបូឌា) អ៊ីន ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ...៤៣៣...ឧស.ឥ.ក.រ.២០៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៦

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន អ៊ីលីត (ខេមបូឌា)។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីលីត (ខេមបូឌា) (ELITE (CAMBODIA) CO., LTD.) តំណាងដោយ លោក **CHEN YEN YEO** បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន (ស្វាយរៀង) សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ អ៊ីលីត (ខេមបូឌា) "

